ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែកក្កដា ឆ្នាំ២០១៩

នៅក្នុងខែកក្កដា ឆ្នាំ២០១៩នេះ ព្រឹទ្ធសភាបានបំពេញការកិច្ចដូចតទៅៈ

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន :**

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន ០២លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមក្នុងព្រះរាជពិធីបុណ្យ "វុទ្ធទិវា" ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណា **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ប្រារព្ធឡើងនៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរណ៍ ខេត្តក្រចេះ

-អញ្ជើញជាអធិបតីថ្លែងសន្ទរកថាបើកសិក្ខាសាលាស្តីពី ក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs) ឆ្នាំ២០១៦-២០៣០

-អញ្ជើញចូលរួមពិធីវាយកូនហ្គោលមិត្តភាព ដើម្បីរំលឹកខួបអនុស្សាវរីយ៍លើកទី៦០ នៃទំនាក់ទំនងការទូតរវាងឥណ្ឌូនេស៊ី និងកម្ពុជា នៅ Grand Phnom Penh Golt Club

-អញ្ជើញចុះពិនិត្យការដ្ឋានកំពុងសាងសង់ និងតម្លើងម៉ាស៊ីនបូមទឹកបន្ថែមនៅបរិវេណស្ថានីយ៍បូមទឹកបឹងទំពុន និងជួបសំណេះសំណាលសួរសុខទុក្ខបងប្អូនបុគ្គលិកកម្មករ ក្នុងសង្កាត់បឹងទំពុនទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

-អញ្ជើញជួបសំណេះសំណាល លើកទឹកចិត្តក្រុមមន្ត្រី យុវជនសង្កាត់ច្បារអំពៅទី១ ដែលចុះធ្វើអនាម័យសម្អាតបរិស្ថានក្នុងភូមិសាស្ត្រមូលដ្ឋាន និងសាកសួរសុខទុក្ខប្រជាពលរដ្ឋនៅខណ្ឌមានជ័យ និងសង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា គោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **ឡាយ អ៊ីពិសិទ្ធ** សមាជិកព្រឹទ្ធសភានីតិកាលទី៤ មណ្ឌលភូមិភាគទី៧ និងលោកជំទាវ **ស៊ីង ស៊ីយុត** សមាជិកព្រឹទ្ធសភា និងជាលេខាធិការគណៈកម្មការ អប់រំ យុវជន កីឡា

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ នៅវត្តបទុមវតី សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមពិធីបុណ្យបូជាសពលោកវរសេនីយ៍ឯក **ស៊ុំ សៀង** អតីតនាយទាហានជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ នៅភូមិទំនប់លើ ឃុំទំនប់ ស្រុកបាធាយ ខេត្តកំពង់ចាម

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៩ច្បាប់ និងជូនជ្រាបជាព័ត៌មានចំនួន៤៧ច្បាប់។

**១.២-ឯកឧត្តម ស៊ឹម កា អនុប្រធានទី១ ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ចំនួន ០២លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **ឡាយ អ៊ីពិសិទ្ធ** សមាជិកព្រឹទ្ធសភានីតិកាលទី៤ មណ្ឌលភូមិភាគទី៧ និងលោកជំទាវ **ស៊ីង ស៊ីយុត** សមាជិកព្រឹទ្ធសភា និងជាលេខាធិការគណៈកម្មការ អប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រារព្ធធ្វើឡើងនៅវត្តបទុមវតី សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៩ច្បាប់ និងជូនជ្រាបជាព័ត៌មាន ចំនួន៣០ច្បាប់។

**១.៣-ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ចំនួន ០១លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញដឹកនាំគណៈប្រតិភូសភាកម្ពុជាចូលរួមសម័យប្រជុំពេញអង្គលើកទី២ នៃវេទិកាអន្តរជាតិលើកទី២ស្តីពី ការអភិវឌ្ឍប្រព័ន្ធសភានិយមមជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោកទីក្រុងម៉ូស្គូ នៅសហព័ន្ធរុស្ស៊ី

-អញ្ជើញចូលរួមសិក្ខាសាលាស្តីពី ការស្វែងយល់ពីការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ក្រោមអធិបតីភាពដ៏

ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសបារាំងទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល

-អញ្ជើញនាំយកទានព្រះវស្សា និងទេយ្យទានប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាអស់កាលត្រីមាស នៅវត្តអូរសោម វត្តប្រាំបីមុំ វត្តដំណាក់រាជា វត្តទេពប្រណម្យ និងវត្តជម្រៀងផ្អែម ព្រមទាំងបានប្រគេនបច្ច័យមួយចំនួនសម្រាប់កសាងសមិទ្ធផលនៅក្នុងវត្តស្ថិតនៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ និងឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ

-អញ្ជើញចូលរួមក្នុងពិធីប្រទានភ្លើងបូជាសពលោកវរសេនីយ៍ឯក **ស៊ុំ សៀង** អតីតនាយទាហានជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងសម្តេចចៅហ្វាវាំង វរវៀងជ័យអធិបតីស្រីឫទ្ធារ **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ស្ថិតនៅភូមិទំនប់លើ ឃុំទំនប់ ស្រុកបាធាយ ខេត្តកំពង់ចាម

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **ឡាយ អ៊ីពិសិទ្ធ** សមាជិកព្រឹទ្ធសភានីតិកាលទី២ មណ្ឌលភូមិភាគទី៧ និងលោកជំទាវ **ស៊ីង ស៊ីយុត** សមាជិកព្រឹទ្ធសភា និងជាលេខាធិការគណៈកម្មការ អប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រារព្ធធ្វើឡើងនៅវត្តបទុមវតី សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៦២ច្បាប់ និងជូនជ្រាបជាព័ត៌មានចំនួន១៦ច្បាប់។

## ២-សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានបើកកិច្ចប្រជុំចំនួន០២លើក ដែលមានរបៀបវារៈដូចខាងក្រោមៈ

១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៩ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនអេសភី អេចភី (ខេមបូឌា)ឯ.ក ក្រុមហ៊ុនស្នេថេក រីញូវេប៊េល ឯ.ក និងក្រុមហ៊ុនស្នេថេក ខូអិលជីឌី

២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៣ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពី វិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

៣-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៣ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩- ២០២៣

៤-កំណត់របៀបវារៈ និងកាលបរិច្ឆេទសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៤។

## ៣-សម័យប្រជុំពេញអង្គព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកសម័យប្រជុំពេញអង្គចំនួន០១លើកដើម្បីពិនិត្យ និងឱ្យយោបល់លើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនអេសគី អេចគី (ខេមបូឌា)ឯ.ក ក្រុមហ៊ុនស្នេថេក រីញូវេប៊េល ឯ.ក និងក្រុមហ៊ុនស្នេថេក ខូអិលធីឌី

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពី វិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩- ២០២៣ ។

## ៤-គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

ក្នុងខែកក្កដានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារតាមតួនាទីភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនយ៉ាងសកម្ម ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោមៈ

### ៤.១-មុខងារនីតិកម្ម

-គណៈកម្មការជំនាញរបស់ព្រឹទ្ធសភា បានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៥ច្បាប់ ។

### ៤.២-មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន០៧ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០៦ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន០៦ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងរបស់ក្រសួង ស្ថាប័នពាក់-

ព័ន្ធចំនួន០៣ករណី និងឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៦ករណី កំពុងពិនិត្យសិក្សាចំនួន០២ករណី ព្រមទាំងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការដើម្បីជូនជ្រាបចំនួន០៤ករណី

-បានធ្វើវេទិកាថ្នាក់ស្រុកស្តីពី ការសិក្សាស្វែងយល់ និងប្រមូលព័ត៌មានលើការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងការផ្តល់ព័ត៌មាន នៅខេត្តត្បូងឃ្មុំ

-អញ្ជើញចូលរួមសិក្ខាសាលាស្តីពី ក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា(CSDGs) ឆ្នាំ២០១៦-២០៣០

-អញ្ជើញចូលរួមសិក្ខាសាលាស្តីពី ការស្វែងយល់អំពីការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

-អញ្ជើញចូលរួមសិក្ខាសាលាស្តីពី អបអរសាទរខួបលើកទី១៣០នៃទិវាសភាអន្តរ-ជាតិរបស់សហភាពអន្តរសភា ក្រោមទិសស្លោក១៣០ឆ្នាំ នៃការផ្តល់អំណាចជូនសមាជិកសមាជិកាសភា

-អញ្ជើញចូលរួមសិក្ខាសាលាស្តីពី ការវិវត្តនៃភូមិសាស្ត្រនយោបាយ និងការលេចឡើងនៃសេដ្ឋកិច្ចឌីជីថល

-អញ្ជើញចូលរួមប្រជុំពិភាក្សាអំពី ការត្រៀមចុះបំពេញបេសកកម្មទៅខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ និងការត្រៀមចូលរួមកិច្ចប្រជុំនៅទីក្រុងហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-អញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្តប៉ៃលិន ក្នុងគោលបំណងជួយជំរុញ និងលើកកម្ពស់ការផ្តល់សេវារដ្ឋបាល ការងារអត្រានុកូលដ្ឋាន និងការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព

-អញ្ជើញចូលរួមប្រជុំពិនិត្យ និងពិភាក្សាស្តីពី ការសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តប្រទេសបារាំងចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខេត្តកំពង់ធំ និងខេត្តព្រះវិហារ និងគម្រោងរៀបចំវេទិកានៅខេត្តមណ្ឌលគិរី

-អញ្ជើញចូលរួមស្តាប់បទបង្ហាញរបស់លោក Niccolo Rinaldi ប្រធានអង្គភាពគោលនយោបាយក្រៅប្រទេសរបស់សភាអឺរ៉ុបស្តីពី បទពិសោធន៍ការរៀបចំកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន៨៩លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និង

ព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោល-នយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗ សរុបចំនួន៩៤លើក ។

**៥- កិច្ចសហប្រតិបត្តិការអន្តរជាតិ**

-លោកជំទាវ **ទី បូរ៉ាស៊ី** អញ្ជើញបំពេញទស្សនកិច្ចសិក្សា និងផ្លាស់ប្តូរបទពិសោធន៍ការងារនៅសភាក្រុមប្រឹក្សានយោបាយប្រជាជនចិន នៃសាធារណរដ្ឋប្រជាមានិតចិន

-ឯកឧត្តម **ជា ជេដ្ឋ** និងឯកឧត្តម **ម៉ែន ស៊ីផាន់** អញ្ជើញទៅទស្សនកិច្ចសិក្សាស្វែងយល់អំពី "ដំណើរការ និងនីតិវិធីនៃការគ្រប់គ្រងរបបសន្តិសុខសង្គម និងការអនុវត្តការងារជាក់ស្តែងរបស់គណៈកម្មាធិការក្រមសីលធម៌សម្រាប់សមាជិកព្រឹទ្ធសភាបារាំង" នៅសាធារណរដ្ឋបារាំង

-ឯកឧត្តម **ឈិត គឹមយាត** អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកកិច្ចការនយោបាយរបស់សភាតំបន់អាស៊ី (APA) នៅទីក្រុងអ៊ីស្លាហាន់ នៃសាធារណរដ្ឋឥស្លាមអ៊ីរ៉ង់

-ឯកឧត្តម **ស្រី បេន** អញ្ជើញចូលរួមវេទិកាអន្តរជាតិលើកទី២ស្តីពី ការអភិវឌ្ឍប្រព័ន្ធសភានិយម នៅទីក្រុងមូស្គូ នៃសហព័ន្ធរុស្ស៊ី

-ឯកឧត្តម **ម៉ាន់ ឈឿន** អញ្ជើញចូលរួមសិក្ខាសាលាស្តីពី សហគមន៍អាស៊ានក្នុងភាពជាដៃគូដើម្បីអភិវឌ្ឍលំនៅដ្ឋាន នៅទីក្រុងបាងកក នៃព្រះរាជាណាចក្រថៃឡង់ដ៍

-លោកជំទាវ **ឃួន ឃុនឌី** និងលោកជំទាវ **មុំ សណ្ដាប់** អញ្ជើញចូលរួមកិច្ចប្រជុំកំពូល Women Political Leader 2019 នៅទីក្រុងតូក្យូ នៃព្រះរាជាណាចក្រជប៉ុន។ ✓

ថ្ងៃ ចន្ទ ៥កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩

**ជ.ប្រធានព្រឹទ្ធសភា**
**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូនៈ
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ